ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងរ៉ែ និងថាមពល
Ministry of Mines and Energy
លេខ: ...៦៦សស........

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ២០១៦

# សេចក្ដីប្រកាសព័ត៌មាន

## ក្រសួងរ៉ែនិងថាមពលស្វាគមន៍ការចូលរួមរបស់ប្រជាពលរដ្ឋ អង្គការមិនមែនរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍នានា លើវិស័យរ៉ែនិងថាមពល

កន្លងមក ក្រសួងរ៉ែនិងថាមពល តែងតែសហការជាមួយប្រជាពលរដ្ឋ សង្គមស៊ីវិល សមាគម អង្គការមិនមែនរដ្ឋាភិបាលជាតិ-អន្តរជាតិ និងដៃគូអភិវឌ្ឍន៍នានា ដែលពាក់ព័ន្ធទាំងអស់ ដោយស្ដាប់នូវយោបល់ និងទទួលយកព័ត៌មាន តាមរយៈប្រព័ន្ធទូរស័ព្ទ Hotline (095 727 727) និងតាមរយៈប្រអប់សំបុត្ររបស់ក្រសួងរ៉ែនិងថាមពល។

ឯកឧត្តម ស៊ុយ សែម រដ្ឋមន្ត្រីនៃក្រសួងរ៉ែនិងថាមពល បានមានប្រសាសន៍ថា "ក្រសួងរ៉ែនិងថាមពល បានត្រៀមខ្លួនរួចជាស្រេចដើម្បីសហការជាមួយសមាគម អង្គការមិនមែនរដ្ឋាភិបាលជាតិ-អន្តរជាតិ និងដៃគូអភិវឌ្ឍន៍នានាដែលមានវត្តមានក្នុងព្រះរាជាណាចក្រកម្ពុជា ក្នុងការចូលរួមថែរក្សា និងអភិវឌ្ឍធនធានធម្មជាតិប្រកបដោយចីរភាព។" ដូច្នេះ ក្រសួងរ៉ែនិងថាមពល សូមលើកទឹកចិត្តដល់ប្រជាពលរដ្ឋគ្រប់រូប សង្គមស៊ីវិល សមាគម អង្គការមិនមែនរដ្ឋាភិបាលជាតិ-អន្តរជាតិ និងភាគីពាក់ព័ន្ធនានា បន្តចូលរួមសហការជាមួយក្រសួងក្នុងការផ្ដល់ព័ត៌មាន និងយោបល់កែលម្អ ដើម្បីក្រសួងមានលទ្ធភាពគ្រប់គ្រាន់ក្នុងការចាត់វិធានការសមស្របចំពោះភាពអសកម្មដែលកើតមានឡើងជាយថាហេតុ។ ដោយឡែក ក្រសួងរ៉ែនិងថាមពល ក៏សូមអំពាវនាវ និងស្នើសុំដល់ភាគីពាក់ព័ន្ធទាំងអស់ ចៀសវាងឱ្យខាងតែបាននូវការប្រព្រឹត្តអំពើនានាដែលបំពានច្បាប់ហួសដែនកំណត់ ដូចជាការដើរតួនាទីជំនួសអាជ្ញាធរមានសមត្ថកិច្ច ជាដើម។

ក្រសួងរ៉ែនិងថាមពល សង្ឃឹមយ៉ាងមុតមាំថា កិច្ចសហការរវាងក្រសួងរ៉ែនិងថាមពល ជាមួយសមាគម អង្គការមិនមែនរដ្ឋាភិបាលជាតិ-អន្តរជាតិ និងដៃគូអភិវឌ្ឍន៍នានា នឹងបន្តយ៉ាងស្អិតរមួតប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផលខ្ពស់ នាពេលអនាគត។

សូមសាធារណជនមេត្តាជ្រាបជាព័ត៌មាន

សូមអរគុណ!

លេខ ៧៩-៨៩ ផ្លូវប៉ាស្ទ័រ (៥១) សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ (៨៥៥)២៣ ២១៩ ៥៧៤ ទូរសារ (៨៥៥)២៣ ២១៩ ៥៨៤
#79-89,Pasteur Street(51),Sangkat Phsar Thmey3,Khan Daun Penh,Phnom PenhTel: (855) 23 219 574 Fax: (855) 23 219 584 www.mme.gov.kh info@mme.gov.kh